ឆ្នាំទី ២ លេខ ១៣ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០២ រាជកិច្ច 

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៦ សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំបុណ្យវិសាខបូជា

## និង

## ព្រះរាជពិធីច្រត់ព្រះនង្គ័ល

xxxxx

✷បុណ្យវិសាខបូជា គឺជាបុណ្យមួយក្នុងបណ្តាបុណ្យធំ១ទាំងឡាយ ក្នុងព្រះពុទ្ធសាសនា ដែលប្រទេសកាន់ព្រះពុទ្ធសាសនាលើសកលលោក តែងប្រារព្ធធ្វើពុំដែលខាន ។

ពិធីនេះ ប្រារព្ធឡើងដើម្បីរំឭកដល់ថ្ងៃជាមហាមង្គលទាំងបី ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រសូតចាកឧទរព្រះមាតាផង ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណផង និងទ្រង់រំលត់ខ័ន្ធចូលកាន់ព្រះបរមនិព្វានផង ។

ចំពោះពុទ្ធសាសនិកខ្មែរយើង ក៏តែងប្រារព្ធធ្វើបុណ្យវិសាខបូជាជារៀងរាល់ឆ្នាំ នៅគ្រប់វត្តអារាមទូទាំងប្រទេស ដោយចាត់ទុកថា នោះជាមហាកុសលដ៏ថ្លៃថ្លាបំផុត ។

រីឯរាជរដ្ឋាភិបាល ក៏បានចាត់ចែងរៀបចំពិធីបុណ្យនេះជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ មុខរាជាយស្ម័យយានកម្ពុជា ដោយមានថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ អ្នកមុខអ្នកការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ពុទ្ធបរិស័ទដ៏ច្រើនកុះករចូលរួម ស្របតាមស្មារតីរដ្ឋធម្មនុញ្ញដែលបានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

ឆ្នាំនេះ បុណ្យវិសាខបូជា នឹងត្រូវប្រព្រឹត្តទៅរយៈពេល ២ថ្ងៃគឺ ថ្ងៃសុក្រ ១៥កើត និងថ្ងៃសៅរ៍ ១រោច ខែពិសាខ ព.ស ២៥៤៦ ត្រូវនឹងថ្ងៃទី ២៦ និងទី ២៧ ខែ មេសា ឆ្នាំ ២០០២ តាមកម្មវិធី ជាក់ស្តែង ។

✷ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជបវេណីដ៏សំខាន់ ក្នុងបណ្តាព្រះរាជពិធីបុណ្យទ្វាទសមាសប្រចាំឆ្នាំ ចាត់ទុកថាជាវប្បមង្គលមួយដ៏ប្រសើររបស់ប្រជារាស្ត្រខ្មែរ ដែលព្រះមហាក្សត្រគ្រប់ព្រះអង្គ តែងដឹកនាំប្រារព្ធធ្វើពុំដែលខាន តាំងពីបុរាណកាលរៀងមក ។

ព្រះរាជពិធីនេះ ប្រព្រឹត្តឡើងដើម្បីជាមង្គលឧទ្ទិសដល់ការធ្វើស្រែចម្ការ និងបួងសួងដល់វត្ថុស័ក្តិសិទ្ធឱ្យបង្អុរទឹកភ្លៀងបរិបូណ៌តាមរដូវកាល អាចបំរើឱ្យវិស័យកសិកម្មគ្រប់ប្រភេទទទួលបានលទ្ធផលខ្ពស់ របស់ប្រជាកសិករយើង ។

ព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំនេះ ប្រព្រឹត្តទៅរយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃ ១-២-៣ រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ២៧-២៨-២៩ ខែមេសា ឆ្នាំ២០០២ ជាទិវាតាំងពិធីច្រត់ព្រះនង្គ័ល ជាភារកិច្ចរបស់លោកអាចារ្យ និង

ក្រុមបារគូ ។ ឯថ្ងៃអង្គារ ៤រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០២ ជាព្រះរាជពិធីច្រត់ព្រះនង្គ័លផ្លូវការ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

ដើម្បីញ៉ាំងឱ្យពិធីទាំងពីរនេះប្រព្រឹត្តទៅយ៉ាងឧឡារិក អធិកអធម សមស្របតាមអត្ថន័យ និងខ្លឹមសារដូចខាងលើ រាជរដ្ឋាភិបាល ដាក់ចេញសារាចរណែនាំដូចខាងក្រោម :

## ១_អំពីបុណ្យវិសាខបូជា

-ក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីបុណ្យវិសាខបូជានៅក្នុងព្រះបរមរាជវាំង តាមព្រះរាជបវេណី និងតាមការសព្វព្រះរាជហឫទ័យរបស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងធម្មការ និងសាសនា និងសាលាក្រុងភ្នំពេញ ចាត់តាំងពិធីបុណ្យវិសាខបូជាជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ មុខរាជាយស្ថ័យយានកម្ពុជា ដោយមានការអញ្ជើញថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងពុទ្ធបរិស័ទចូលរួមឱ្យបានច្រើនកុះករតាមកម្មវិធីជាក់ស្តែង ។

-គ្រប់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ត្រូវរៀបចំឱ្យមានកម្មវិធីបុណ្យវិសាខបូជាជាផ្លូវការ នៅទីវត្តណាមួយដែលអាចដំណើរការបានដោយនិមន្តមន្ត្រីសង្ឃ អញ្ជើញថ្នាក់ដឹកនាំ ខេត្ត-ក្រុង ស្រុក-ខណ្ឌ មន្ត្រីរាជការក្រោមឱវាទ អ្នកមុខអ្នកការ ព្រមទាំងពុទ្ធបរិស័ទចូលរួមឱ្យបានច្រើនកុះករ ។

-ក្រសួងធម្មការ និងសាសនា ត្រូវណែនាំគ្រប់អង្គភាពក្រោមឱវាទ សហការជាមួយពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ ចាត់តាំងពិធីបុណ្យវិសាខបូជាឱ្យបានផុលផុស ដើម្បីលើកកំពស់តួនាទីដ៏សំខាន់របស់ព្រះពុទ្ធសាសនា និងប្រពៃណីដ៏ល្អរបស់ជាតិយើង ។

## ២_អំពីព្រះរាជពិធីច្រត់ព្រះនង្គ័ល

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សាលាក្រុងភ្នំពេញ និងក្រសួងពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីច្រត់ព្រះនង្គ័លនៅទីព្រះស្រែវាលព្រះមេរុ ឱ្យបានឧឡារិកអធិកអធម ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ដោយមានការយាងនិងអញ្ជើញចូលរួម ពីព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជារាស្ត្រតាមចំនួនកំណត់ជាក់ស្តែង ដើម្បីរក្សាឱ្យបានគង់វង្សនូវព្រះរាជបវេណីពីបូរាណរបស់ព្រះអតីតមហាក្សត្រនៃយើង ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយសម្ភារៈ ថវិកាសម្រាប់បំរើពិធីបុណ្យទាំងពីរឱ្យបានទាន់ពេលវេលា ធានារូបភាពចាត់តាំងស្របតាមគោលបំណង និងសំណូមពរ ។

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងក្រុមសិល្បៈសំដែងជូនមហាជនទស្សនា អបអរសាទរព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅថ្ងៃអង្គារ ទី ៣០ ខែ មេសា ឆ្នាំ ២០០២ នៅទីព្រះស្រែវាលព្រះមេរុ ។

-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាព ក្រោមឱវាទ ឱ្យសហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ធានាសុវត្ថិភាព ក្នុងបុណ្យទាំងពីរឱ្យបានល្អប្រសើរ ។

-ក្រសួងពត៌មាន ត្រូវចាត់តាំងបណ្ដាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ចុះធ្វើសកម្មភាពយកពត៌មាន ដោយថ្លៃប្រឌិត ធ្វើការផ្សព្វផ្សាយទូលាយ ទាំងរូបភាពចាត់តាំង និងទាំងខ្លឹមសារនៃពិធីបុណ្យទាំងពីរ មុន-ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យ ។

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងមន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជាពលរដ្ឋ ចូលរួមតាមការកំណត់ និងត្រូវមានកម្មវិធីដាក់ស្លែង ព្រមទាំងបំផុសឱ្យតុបតែងលំអ ចងបដា ពាក្យស្លោក ទង់ជាតិ នៅតាមអគារសាធារណៈ រោងចក្រ សហគ្រាស និងគ្រប់គេហដ្ឋាន អបអរសាទរបុណ្យទាំងពីរខាងលើ ឱ្យបានល្អប្រសើរ ស័ក្តិសមជាទិវាបុណ្យជាតិ ដ៏រុងរឿង ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេស នឹងចាត់តាំងអនុវត្តតាមស្មារតីសារាចរណែនាំនេះ សម្រេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- **ក្រសួងព្រះបរមរាជវាំង**
- **អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
- **អគ្គលេខាធិការដ្ឋានរដ្ឋសភា**
- **ទីស្ដីការគណៈរដ្ឋមន្ត្រី**
- **ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី**
- **គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង**
  **"ដើម្បីសហការអនុវត្ត"**
- **ឯកសារ-កាលប្បវត្តិ**

## ពាក្យស្លោកសំរាប់បុណ្យវិសាខបូជា

-----

-អបអរសាទរពិធីបុណ្យវិសាខបូជា ឆ្នាំមមី ចត្វាស័ក ព.ស ២៥៤៦
-សូមថ្វាយព្រះពរសម្ដេចឪ សម្ដេចម៉ែ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
-ជយោ ! ព្រះរាជាណាចក្រកម្ពុជា
-ជាតិ សាសនា ព្រះមហាក្សត្រ
-ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ
-នត្ថិ សន្តិ បរំ សុខំ គ្មានសុខអ្វីស្មើនឹងសេចក្ដីស្ងប់
-សុខោ បុញ្ញស្ស ឧច្ចយោ ការសន្សំបុណ្យនាំមកនូវសេចក្ដីសុខ
-អហឹង្សា ជាគោលការណ៍រួមនៃព្រះពុទ្ធសាសនា
-សុភមង្គល និងអភិវឌ្ឍន៍ ជាសំណូមពរដ៏ពិសិដ្ឋរបស់ព្រះពុទ្ធសាសនា
-សូមព្រះធម៌របស់ព្រះពុទ្ធបរមគ្រូជ្រួតជ្រាបគ្រប់មនុស្សទូទៅ
-ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍
-សម្ដេចឪ សម្ដេចម៉ែ ជាព្រះរាជអគ្គពុទ្ធសាសនូបត្ថម្ភក៍

## ពាក្យស្លោកសំរាប់ពិធីច្រត់ព្រះនង្គ័ល

-----

១- អបអរសាទរ ព្រះរាជពិធីច្រត់ព្រះនង្គ័ល " ៣០-០៤-២០០២ "
២- ជយោ ! សម្ដេចព្រះបិតាកសិកម្មជាតិ
៣- កសិកម្ម ជាមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ
៤- អភិវឌ្ឍន៍វិស័យកសិកម្ម គឺអភិវឌ្ឍន៍សង្គមជាតិ
៥- កសិកម្មល្អូតលាស់ ជីវភាពប្រជាកសិកររីកចំរើន
៦- រួមគ្នាស្ដារ និងអភិវឌ្ឍន៍វិស័យកសិកម្ម
៧- ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាវប្បមង្គលដ៏ឧត្ដម
៨-សូមថ្វាយព្រះពរ សម្ដេចឪ សម្ដេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ
៩-ជយោ ! រាជរដ្ឋាភិបាលសេដ្ឋកិច្ច
១០-ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍